ធិការដ្ឋាននៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈនិងលោក មាស គីមហេង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានិងចុះហត្ថលេខាតទៅ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| --- | --- |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

# សេចក្តីសំរេច

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ១៩៩៤*

## សេចក្តីសំរេច លេខ ៦៧ ស ស រ
## ស្តីពីការកំណត់តម្លៃលក់ទឹកស្អាត

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ក្រសួងមហាផ្ទៃ លេខ២៥១សស,មផចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ១៩៩៤

**សំរេច**

ប្រការ ១ : កំណត់តម្លៃលក់ទឹកស្អាតនៅរាជធានីភ្នំពេញ ដូចតទៅ :

- តម្លៃ ២៥០រ០០/ម៉ែត្រគីប ( ពីររយហាសិបរៀលគត់ ក្នុង១ម៉ែត្រគីប ) សំរាប់លក់បំរើ អោយជីវភាពប្រជាពលរដ្ឋ និង អង្គភាពបុព្វហេតុរដ្ឋបាល ។

- តម្លៃ៧០០៖០០ / ម៉ែត្រគីប ( ប្រាំពីររយរៀលគត់ក្នុង ១ ម៉ែត្រគីប ) សំរាប់បំរើអោយកន្លែង ផលិតកម្ម - អាជីវកម្ម - សេវាកម្មឯកជន និងកន្លែង សេវាកម្មស្វយ័តរបស់រដ្ឋ ដែលប្រើប្រាស់ធនធានទឹកស្អាតជាមូលដ្ឋាន ។

ប្រការ ២ : អង្គភាពរដ្ឋាករទឹក មានភារកិច្ចផលិតទឹក និង ផ្គត់ផ្គង់អោយបានគ្រប់គ្រាន់ ដល់អ្នកប្រើប្រាស់ទឹក ។

ប្រការ ៣ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងបណ្តាក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្ត សេចក្តីសំរេចនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

*រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៩៤*

*សេចក្តីសំរេចលេខ ៦៨ ស ស រ*

ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះ មហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- ផ្អែកតាមការចាំបាច់